**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន

នៅរសៀលថ្ងៃទី ៧ ខែមីនា ឆ្នាំ២០២២ ក្រុមការងារប្រឆាំងការបោសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (កបទ.សអ) បានរៀបចំសិក្ខាសាលា តាមប្រព័ន្ធវីដេអូ ដើម្បីផ្សព្វផ្សាយ «ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ» ក្រោមអធិបតីភាពរបស់ ឯកឧត្តមបណ្ឌិត ញឹម ខេមរា រដ្ឋលេខាធិការ ក្រសួងកបទ.សអ ដែលជាប្រធានក្រុមការងារខាងលើ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រី នៃក្រសួងកបទ.សអ និងតំណាងមកពីក្រសួងទេសចរណ៍ និងក្រសួងមហាផ្ទៃ សរុបចំនួន៥២នាក់។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងស្របតាមកាតព្វកិច្ចរបស់កម្ពុជាក្នុងការអនុវត្តសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអ.ស.ប ពាក់ព័ន្ធនឹងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ហើយការអនុវត្តកាតព្វកិច្ចនេះ ក៏ឆ្លើយតបទៅនឹងស្តង់ដាររបស់ក្រុមការងារហិរញ្ញវត្ថុ (Financial Action Task Force – FATF)។ សិក្ខាសាលាបានផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដើម្បីពង្រឹងការយល់ដឹងអំពីខ្លឹមសារ និងក្របខ័ណ្ឌគតិយុត្តិនៃច្បាប់នេះ ដល់មន្ត្រីក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដែលអាចឆ្លើយតបទៅនឹងវិធានការបង្ការ ទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ សិក្ខាកាមបានពិភាក្សា និងផ្លាស់ប្តូរមតិផ្តោតលើនីតិវិធីរបស់កម្ពុជាក្នុងការអនុវត្តតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអ.ស.ប។

នៅចុងបញ្ចប់នៃសិក្ខាសាលា សិក្ខាកាមត្រូវបានលើកទឹកចិត្តឱ្យជួយផ្សព្វផ្សាយបន្តឱ្យកាន់តែទូលំទូលាយដល់សហការី និងសាធារណជន ដើម្បីជានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការងារនេះ៕

ថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២២

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh